អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១

## សេចក្តីប្រកាសព័ត៌មាន
## សំណុំរឿង ០០២ ត្រូវបានបញ្ជូនទៅជំនុំជម្រះ

ថ្ងៃនេះ អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានបញ្ជាក់សម្រេច និងបានកែប្រែផ្នែកខ្លះនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះក្តីលើករណីជនជាប់ចោទ អៀង សារី, អៀង ធីរិទ្ធ, ខៀវ សំផន, និង នួន ជា។ អង្គបុរេជំនុំជម្រះបានចេញដីកាបង្គាប់ឲ្យបញ្ជូនជនជាប់ចោទទៅជំនុំជម្រះ និងបន្តដាក់ជនជាប់ចោទក្នុងមន្ទីរឃុំឃាំងបណ្តោះអាសន្ន រហូតដល់ពេលមានការនាំខ្លួនពួកគាត់ទៅជំនុំជម្រះនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះបានបញ្ចូលបទចោទនានា រួមមាន ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អំពើប្រល័យពូជសាសន៍ អំពើបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវឆ្នាំ១៩៤៩ និងអំពើមនុស្សឃាត អំពើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញខាងសាសនា ដូចមានចែងក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦។

សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយ ដោយមានការចោទប្រកាន់បឋមទៅលើជនជាប់ចោទនៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០។ ជនជាប់ចោទទាំងបួនរូបបានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយទៅអង្គបុរេជំនុំជម្រះ។

អង្គបុរេជំនុំជម្រះបានបដិសេធបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ហើយទទួលយកផ្នែកខ្លះនៃបណ្តឹងឧទ្ធរណ៍របស់ អៀង សារី, អៀង ធីរិទ្ធ, និង នួន ជា។ នៅត្រង់ផ្នែកដែលអាចទទួលយកបាន អង្គបុរេជំនុំជម្រះបានបដិសេធមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ ដោយត្រូវធ្វើការកែប្រែចំនួនពីរចំណុច។ ចំណុចទីមួយ អង្គបុរេជំនុំជម្រះបានបង្គាប់ឲ្យមានការកែប្រែដីកាដំណោះស្រាយ ដោយមានការបញ្ជាក់ច្បាស់លាស់អំពីលក្ខខណ្ឌតម្រូវឲ្យមានអត្ថិភាពនៃទំនាក់ទំនង រវាងអំពើជាមូលដ្ឋាននៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងជម្លោះប្រដាប់អាវុធ។

ចំណុចទីពីរ អង្គបុរេជំនុំជម្រះក៏បានយល់ឃើញថាអំពើរំលោភសេពសន្ថវៈពុំទាន់មានអត្ថិភាពថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្នុងរយៈកាលពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ នោះទេ ប៉ុន្តែអំពើរំលោភសេពសន្ថវៈអាចត្រូវបានចាត់ទុកថាជា “អំពើអមនុស្សធម៌ដទៃទៀត” ក្នុងនិយមន័យច្បាប់នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ ដីកាដំណោះស្រាយត្រូវបានកែប្រែត្រង់ចំណុចទាំងពីរនេះ។ អង្គបុរេជំនុំជម្រះនឹងចេញសាលដីកាដោយមានសំអាងហេតុលើបណ្តឹងឧទ្ធរណ៍ នៅពេលក្រោយ។

ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌដង្កោ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣-២១៩-៨១៤ ទូរសារ (៨៥៥) ២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh

ចំពោះព័ត៌មានបន្ថែម សូមទាក់ទង:


លោក **រាជ សម្បត្តិ**
ប្រធានផ្នែកកិច្ចការសាធារណៈ
ទូរស័ព្ទចល័តលេខ +855(0) 12 488 156
ទូរសារលេខ +855(0)23 219 841
សារអេឡិចត្រូនិច reach.sambath@eccc.gov.kh

លោក **ឌីម សុវណ្ណារ៉ុំ**
មន្ត្រីទទួលបន្ទុកការងារព័ត៌មាន
ទូរស័ព្ទចល័តលេខ +855(0) 12 488 094
ទូរសារលេខ +855(0)23 219 841
សារអេឡិចត្រូនិច dim.sovannarom@eccc.gov.kh

---

លោក **ឡាស អូលសិន**
មន្ត្រីទទួលផ្នែកទំនាក់ទំនងផ្លូវច្បាប់
ទូរស័ព្ទចល័តលេខ +855(0) 12 488 023
ទូរសារលេខ +855(0)23 219 841 លេខបន្ត 6169
សារអេឡិចត្រូនិច olsenl@un.org

លោកស្រី **យូកូ មេដា**
មន្ត្រីទទួលបន្ទុកផ្នែកកិច្ចការសាធារណៈ
ទូរស័ព្ទចល័តលេខ +855(0) 12 488 319
ទូរសារលេខ +855(0)23 219 841 លេខបន្ត 6139
សារអេឡិចត្រូនិច maeday@un.org